# បំណងប្រាថ្នា

អែលឌើរ ដាល្លិន អេក អូក
នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់

*ដើម្បីសម្រេចជោគវាសនាដ៏អស់កល្បរបស់យើង យើងត្រូវប៉ងប្រាថ្នា ហើយខិតខំស្វែងរកគុណសម្បត្តិដែលធ្វើឲ្យប្រែក្លាយជាមនុស្សដែលមានជីវិតអស់កល្បជានិច្ច ។*

ខ្ញុំត្រូវបានជ្រើសរើសឲ្យនិយាយអំពីសារៈសំខាន់នៃ*បំណងប្រាថ្នា ។* ខ្ញុំសង្ឃឹមថា យើងម្នាក់ៗនឹងគិតនៅក្នុងដួងចិត្ត ដើម្បីកំណត់ថាតើអ្វីទៅជាបំណងប្រាថ្នាពិតរបស់យើង ហើយតើយើងដាក់លំដាប់នៃបំណងប្រាថ្នាដ៏សំខាន់បំផុតតាមរបៀបណា ។

បំណងប្រាថ្នាទាំងឡាយចង្អុលបង្ហាញអំពីអាទិភាពរបស់យើង អាទិភាពទាំងឡាយបង្កើតជាការជ្រើសរើសរបស់យើង ហើយការជ្រើសរើសកំណត់សកម្មភាពរបស់យើង ។ បំណងប្រាថ្នាដែលយើងធ្វើអនុវត្តតាម កំណត់នូវការផ្លាស់ប្តូរ ភាពជោគជ័យ និងការប្រែក្លាយរបស់យើង ។

ដំបូង ខ្ញុំសូមនិយាយអំពីបំណងប្រាថ្នាធម្មតាមួយចំនួន ។ ជាមនុស្សរមែងស្លាប់ យើងមានតម្រូវការខាងរូបកាយមួយចំនួន ។ បំណងប្រាថ្នាដើម្បីបំពេញតាមតម្រូវការទាំងនេះបានបង្កើតជាការជ្រើសរើស ហើយកំណត់នូវសកម្មភាពរបស់យើង ។ មានឧទាហរណ៍ចំនួនបី ដែលនឹងបង្ហាញអំពីរបៀបដែលពេលខ្លះ យើងធ្វើឲ្យបំណងប្រាថ្នាទាំងនេះ លុបបំបាត់នូវបំណងប្រាថ្នាផ្សេងទៀត ដែលយើងគិតថា សំខាន់ជាង ។

ទីមួយ ម្ហូបអាហារ ។ យើងមានតម្រូវការចម្បងសម្រាប់អាហារ ប៉ុន្តែជួនកាល បំណងប្រាថ្នានោះ អាចនឹងត្រូវគ្របដណ្តប់ដោយបំណងប្រាថ្នាចង់តមអាហារជាខ្លាំង ។

ទីពីរ ទីជម្រក ។ កាលពីនៅក្មេងអាយុ 12 ឆ្នាំ ខ្ញុំគ្មានបំណងប្រាថ្នាចង់បានទីជម្រកទេ ដោយសារខ្ញុំមានបំណងប្រាថ្នាចង់បំពេញតាមតម្រូវការក្រុមកាយឫទ្ធិ ដោយទៅដេកនៅក្នុងព្រៃខ្លាំងជាង ។ ខ្ញុំជាក្មេងប្រុសម្នាក់ក្នុងចំណោមក្មេងប្រុសមួយចំនួន ដែលចាកចេញពីត្រសាលដ៏សុខស្រួលហើយបានរកឃើញវិធីមួយដើម្បីធ្វើទីជម្រកនិងធ្វើគ្រែបុរាណមកពីដើមឈើដែលយើងអាចរកបាន ។

ទីបី ការទទួលដំណេក ។ សូម្បីតែបំណងប្រាថ្នាដ៏ចម្បងនេះ ក៏អាចគ្របដណ្តប់ជាបណ្តោះអាសន្នដោយជាបំណងប្រាថ្នាសំខាន់ជាង គ្របលើភាពជាបណ្តោះអាសន្ន ។ ក្នុងនាមជាទាហានវ័យក្មេងនៃកងឆ្មាំជាតិក្នុងរដ្ឋ
យូថាហ៍ ខ្ញុំបានរៀនពីគំរូមួយ មកពីនាយទាហានជើងចាស់ម្នាក់ ។

នៅខែដំបូងនៃសង្គ្រាមកូរ៉េ រីឆហ្វៀលដែលជាផ្នែកកាំភ្លើងធំរបស់កងឆ្មាំជាតិក្នុងរដ្ឋយូថាហ៍ ត្រូវបានហៅឲ្យចេញប្រតិបត្តិការ ។ ក្រុមកាំភ្លើងធំនេះ ត្រូវបានបញ្ជាដោយមេទ័ពឈ្មោះ រ៉េយ ខក់ ហើយមានយុវជនមរមនប្រហែលជា 40 នាក់ ។ បន្ទាប់ពីការហ្វឹកហាត់បន្ថែម និងការពង្រឹងដោយទាហានបម្រុង មកពីកន្លែងផ្សេង មិនយូរប៉ុន្មានពួកគេត្រូវបានបញ្ជូនទៅប្រទេសកូរ៉េ ជាកន្លែងដែលពួកគេនឹងជួបការប្រយុទ្ធដ៏ខ្លាំងក្លាក្នុងសង្គ្រាមនោះ ។ នៅក្នុងសមរភូមិមួយ ពួកគេត្រូវវាយច្រានដោយទ័ពថ្មើរជើងរបស់សត្រូវរាប់រយនាក់ ដែលចូលមកឈ្លានពានដោយផ្ទាល់ ជាប្រភេទការវាយប្រហារដ៏ធំ ហើយបានបំផ្លាញកងទ័ពកាំភ្លើងធំម្ខាងទៀត ។

តើរឿងនេះវាមានទំនាក់ទំនងអ្វីទៅ នឹងការយកឈ្នះលើបំណងប្រាថ្នានៃការចង់ដេក ? នៅពេលយប់ដ៏គ្រោះថ្នាក់មួយ ពេលទ័ពថ្មើរជើងរបស់សត្រូវបានសម្រុកមកនៅជួរមុខ និងតាមតំបន់ខាងក្រោយ ដែលកាន់កាប់ដោយក្រុមកាំភ្លើងធំ នោះមេទ័ព បានដាក់វិទ្យុទាក់ទងនៅក្នុងត្រសាលរបស់គាត់ ហើយបានបញ្ជាឲ្យទាហានដែលដើរល្បាតតាមបរិវេណ រាយការណ៍មកគាត់ដោយផ្ទាល់ រាល់មួយម៉ោងម្តងពេញមួយយប់ ។ ការធ្វើដូច្នេះ ដើម្បីកុំឲ្យពួកគេដេក ប៉ុន្តែវាក៏រំខានដល់ការដេករបស់មេទ័ព ខក់ ផងដែរ ។

ខ្ញុំបានសួរគាត់ថា « តើលោកអាចធ្វើដូច្នោះបានដោយរបៀបណា ? » ។ ចម្លើយរបស់គាត់បានបង្ហាញនូវអំណាចនៃបំណងប្រាថ្នាក្នុងការយកឈ្នះ ។

« ខ្ញុំបានដឹងថា បើយើងបានត្រឡប់ទៅផ្ទះវិញ ខ្ញុំនឹងជួបឪពុកម្ដាយរបស់យុវជនទាំងនោះ នៅតាមផ្លូវក្នុងទីក្រុងតូចរបស់យើង ហើយខ្ញុំមិនចង់ជួបនឹងពួកគេឡើយ បើកូនប្រុសពួកគេមិនអាចត្រឡប់ទៅផ្ទះវិញ ដោយសារតែខ្ញុំមិនបានបំពេញកាតព្វកិច្ចខ្ញុំក្នុងនាមជាមេទ័ពរបស់គេនោះ » ។ [1]

នោះគឺជាគំរូមួយដ៏ល្អនៃអំណាចនៃបំណងប្រាថ្នាដែលគ្របដណ្ដប់លើអាទិភាព និងសកម្មភាពទាំងឡាយ !នោះគឺជាគំរូដ៏មានអានុភាពសម្រាប់យើងទាំងអស់គ្នាដែលមានទំនួលខុសត្រូវសម្រាប់សុខុមាលភាពអ្នកដទៃ ---ក្នុងនាមជា ឪពុកម្ដាយ ពួកអ្នកដឹកនាំ និងពួកគ្រូបង្រៀនក្នុងសាសនាចក្រ !

នៅទីបំផុត នៅព្រឹកព្រលឹមបន្ទាប់ពីការមិនបានដេក ពេញមួយយប់របស់គាត់ មេទ័ព ខក់ បានដឹកនាំទ័ពរបស់គាត់ វាយតបទៅលើទ័ពថ្មើរជើងរបស់សត្រូវវិញ ។ ពួកគេចាប់បានអ្នកទោស 800 នាក់ ហើយរងរបួសតែពីរនាក់គត់ ។ មេទ័ព ខក់ ត្រូវបានបំពាក់គ្រឿងឥស្សរិយយសសម្រាប់ភាពក្លាហាន ហើយក្រុមកាំភ្លើងធំរបស់គាត់ បានទទួលគុណកថាមកពីប្រធានាធិបតី ចំពោះភាពជាវីរបុរសដ៏អស្ចារ្យរបស់ពួកគេ ។ ហើយដូចជា កងទ័ពកំលោះរបស់ហេលេមិនផងដែរ ( សូមមើល អាលម៉ា 57:25–26 ) ពួកគេបានត្រឡប់ទៅផ្ទះវិញទាំងអស់គ្នា ។ [2]

ព្រះគម្ពីរមរមនមានការបង្រៀនជាច្រើនអំពីសារៈសំខាន់នៃបំណងប្រាថ្នា ។ បន្ទាប់ពីការទូលអង្វរដល់ព្រះអម្ចាស់ជាច្រើនម៉ោង អេណុស ត្រូវបានប្រាប់ថាអំពើបាបរបស់គាត់ត្រូវបានអត់ទោសឲ្យ ។ បន្ទាប់មក គាត់ « ចាប់ផ្ដើមមានអារម្មណ៍ប្រាថ្នាចង់បាន » សុខុមាលភាពដល់បងប្អូនរបស់គាត់( អេណុស 1:9 ) ។ គាត់បានសរសេរថា ៖ « ហើយ . . . បន្ទាប់ពីខ្ញុំបានអធិស្ឋាន ហើយធ្វើការដោយអស់ពីចិត្ត នោះព្រះអម្ចាស់ទ្រង់មានបន្ទូលមកខ្ញុំថា ៖ យើងនឹងប្រទានដល់អ្នកស្របតាមសេចក្ដីប៉ងប្រាថ្នាទាំងឡាយរបស់អ្នក ដោយសារសេចក្ដីជំនឿរបស់អ្នក » ( ខ. 12 ) ។ សូមកត់សំគាល់នូវសារៈសំខាន់ចំនួនបីដែលកើតឡើងមុនពរជ័យដែលបានសន្យា គឺ ៖ បំណងប្រាថ្នា ការងារ និងសេចក្ដីជំនឿ ។

នៅក្នុងទេសនកថារបស់គាត់ពីជំនឿ អាលម៉ា បង្រៀនថា ជំនឿមិនអាចចាប់ផ្ដើម « ក្រៅពីការចង់ជឿ » នោះទេ បើសិនជាយើងនឹង « សូមឲ្យចំណង់នេះមាននៅក្នុងខ្លួន [ យើង ] » ( អាលម៉ា 32:27 ) ។

ការបង្រៀនដ៏អស្ចារ្យមួយទៀតអំពីបំណងប្រាថ្នា ជាពិសេស អំពីអ្វីដែលគួរតែជាបំណងប្រាថ្នាដ៏ធំបំផុតរបស់យើង កើតមាននៅក្នុងបទពិសោធន៍របស់ស្ដេចសាសន៍លេមិន ដែលត្រូវបានបង្រៀនដោយអ្នកផ្សព្វផ្សាយសាសនាឈ្មោះអើរ៉ុន ។ នៅពេលការបង្រៀនរបស់អើរ៉ុន ធ្វើឲ្យទ្រង់ចាប់អារម្មណ៍ ស្ដេចបានសួរថា « តើយើងត្រូវធ្វើអ្វីខ្លះ ដើម្បីឲ្យយើងអាចបានកើតពីព្រះ » ហើយ « អាចបានជីវិតដ៏នៅអស់កល្បជានិច្ច ? » (អាលម៉ា 22:15) ។ អើរ៉ុនបានឆ្លើយថា ៖ « បើសិនជាទ្រង់មានបំណងចង់បានការណ៍នេះ . . .បើសិនជាទ្រង់ប្រែចិត្តពីអំពើបាបទាំងអស់របស់ទ្រង់ ហើយក្រាបចំពោះព្រះ ហើយអំពាវនាវដល់ព្រះនាមទ្រង់ដោយនូវសេចក្ដីជំនឿដោយជឿថា ទ្រង់នឹងទទួល ពេលនោះទ្រង់នឹងទទួលនូវសេចក្ដីសង្ឃឹមដែលទ្រង់ប៉ងប្រាថ្នា » ( ខ. 16 ) ។

ស្ដេចបានធ្វើតាម ហើយបានប្រកាសនៅក្នុងការអធិស្ឋានដ៏អស្ចារ្យថា « ទូលបង្គំនឹងបោះបង់ចោលអស់ទាំងអំពើបាបរបស់ទូលបង្គំ ដើម្បីឲ្យបានស្គាល់ទ្រង់ ហើយដើម្បីទូលបង្គំអាចបានប្រោសឡើងពីស្លាប់ ... » ( ខ. 18 ) ។ ដោយការប្ដេជ្ញាចិត្ត និងការស្គាល់ពីបំណងប្រាថ្នាដ៏ធំបំផុតរបស់ខ្លួន នោះការអធិស្ឋានរបស់ទ្រង់ត្រូវបានឆ្លើយតបដោយអព្ភូតហេតុ ។

ព្យាការី អាលម៉ា មានបំណងប្រាថ្នាយ៉ាងខ្លាំង ដើម្បីប្រកាសអំពីការប្រែចិត្តដល់ប្រជាជនទាំងអស់ ប៉ុន្តែគាត់បានយល់ថា គាត់មិនគួរប្រាថ្នាចង់បានអំណាចនៃការបង្ខំ ដើម្បីធ្វើការនេះទេ គាត់បានបញ្ចប់ថា « ព្រះដ៏យុត្តិធម៌ . . .ប្រទានឲ្យមនុស្សតាមបំណងរបស់គេ ទោះជាសេចក្ដីស្លាប់ ឬសេចក្ដីរស់ក្ដី » ( អាលម៉ា 29:4 ) ។ ស្រដៀងគ្នានេះ នៅក្នុងវិវរណៈសម័យថ្មី ព្រះអម្ចាស់ប្រកាសថា ទ្រង់ « នឹងជំនុំជំរះមនុស្សលោកទាំងអស់ស្របតាមកិច្ចការរបស់ពួកគេ គឺស្របតាមសេចក្ដីប៉ងប្រាថ្នានៃដួងចិត្តរបស់ពួកគេ » ( គ. និង ស. 137:9 ) ។

តើយើងពិតជាបានត្រៀមខ្លួន ដើម្បីទទួលការជំនុំជំរះដ៏អស់កល្បជានិច្ចរបស់យើងចំពោះការដាក់ការសំខាន់ដ៏មហិមា ទៅលើអ្វីដែលយើងប្រាថ្នាពិតដែរឬទេ ?

បទគម្ពីរជាច្រើនបានចែងអំពីអ្វីដែលយើងប៉ងប្រាថ្នាក្នុងន័យថាជាអ្វីដែលយើងស្វែងរក ។ « អ្នកណាដែលឆាប់ស្វែងរកយើង នោះនឹងបានជួបយើង ហើយនឹងមិនត្រូវបោះបង់ចោលឡើយ » ( គ. និង ស. 88:83 ) ។ « ស្វែងរកអំណោយទាននានាដែលវិសេសបំផុតចុះ » ( គ. និង ស. 46:8 ) ។ « អ្នកណាដែល

ព្យាយាមរកនឹងឃើញ » ( នីហ្វៃទី 1 10:19 ) ។ « ចូរចូលមកជិតយើង នោះយើងនឹងចូលទៅជិតអ្នក ចូរព្យាយាមស្វែងរកយើង នោះអ្នករាល់គ្នានឹងបានជួបយើង ចូរសូមនោះអ្នករាល់គ្នា នឹងបានទទួល ចូរគោះ នោះតែងនឹងបានបើកឲ្យអ្នក » ( គ. និង ស. 88:63 )។

ការកែសម្រួលបំណងប្រាថ្នារបស់យើងក្នុងការផ្តល់អាទិភាពខ្ពស់បំផុតចំពោះអ្វីៗដែលអស់កល្ប គឺមិនងាយស្រួលឡើយ ។ យើងត្រូវបានល្បួងឲ្យប៉ងប្រាថ្នានូវរឿងលោកិយបួនយ៉ាង គឺទ្រព្យសម្បត្តិ ភាពលេចធ្លោ អំនួត និងអំណាច ។ យើងអាចប៉ងប្រាថ្នានូវរឿងទាំងនេះ ប៉ុន្តែយើងមិនគួរកំណត់វា ជាអាទិភាពខ្ពស់បំផុតរបស់យើងនោះទេ ។

អស់អ្នកណាដែលប៉ងប្រាថ្នាចង់បានទ្រព្យសម្បត្តិខ្ពស់បំផុត គឺ ធ្លាក់ក្នុងអន្ទាក់នៃសម្ភារនិយម ។ ពួកគេមិនស្តាប់ការព្រមានថា ៖ « ចូរកុំស្វែងរកទ្រព្យសម្បត្តិ ឬវត្ថុទាំងឡាយដែលឥតប្រយោជន៍នៃលោកិយនេះឡើយ » ( អាលម៉ា 39:14 សូមមើល យ៉ាកុប 2:18 ផងដែរ ) ។

អ្នកទាំងឡាយណាដែលប៉ងប្រាថ្នាភាពលេចធ្លោ ឬអំណាច គួរតែធ្វើតាមគំរូរបស់មេទ័ពមរ៉ូណៃដ៏ក្លាហាន ដែលការបម្រើរបស់គាត់ពុំមែនដើម្បី « អំណាច » ឬ « កិត្តិយសនៃលោកិយ » ទេ ( អាលម៉ា 60:36 ) ។

តើយើងអភិវឌ្ឍការប៉ងប្រាថ្នាទាំងឡាយដោយរបៀបណា ? មនុស្សមួយចំនួនតូចជួបវិបត្តិដែលបានលើកទឹកចិត្តដល់ អើរ៉ុន រ៉លស្តុន3 ប៉ុន្តែបទពិសោធន៍របស់គាត់ផ្តល់នូវមេរៀនដ៏មានតម្លៃអំពីអភិវឌ្ឍនភាពនៃបំណងប្រាថ្នា ។ ខណៈដែល រ៉លស្តុន បានដើរភ្នំនៅតាមជ្រលងភ្នំដាច់ស្រយាលនៅប៉ែកខាងត្បូងរដ្ឋយូថាហ៍ នោះមានថ្មទម្ងន់ 363 គីឡូក្រាម មួយដុំបានធ្លាក់មកសង្កត់លើដៃស្តាំគាត់មួយរំពេច ។ គាត់ព្យាយាមដោះខ្លួនតែម្នាក់ឯងរយៈពេលប្រាំថ្ងៃ ។ នៅពេលគាត់ហៀបនឹងចុះចាញ់ ហើយព្រមទទួលយកសេចក្តីស្លាប់ គាត់មានឃើញការនិមិត្តមួយ ថាមានក្មេងប្រុសម្នាក់អាយុ 3 ឆ្នាំ បានរត់មករកគាត់ ហើយបានលើកដៃឆ្វេងគាត់ឡើង ។ ដោយយល់ថា ការនិមិត្តនេះ គឺជាកូនប្រុសនាពេលអនាគតរបស់គាត់ និងជាការអះអាងថា គាត់អាចនៅមានជីវិតនោះ រ៉លស្តុន បានទទួលភាពក្លាហាន ហើយធ្វើសកម្មភាពដើម្បីសង្គ្រោះជីវិតរបស់ខ្លួនភ្លាម មុនពេលគាត់អស់កម្លាំង ។ គាត់បានបំបាក់ឆ្អឹងដៃស្តាំដែលជាប់នឹងថ្ម ដោយប្រើកាំបិតក្នុងដៃ កាត់ដៃនោះចោល ។ ក្រោយមក គាត់ទទួលកម្លាំង ដើម្បីដើរនៅលើចម្ងាយផ្លូវ 8 គីឡូម៉ែត្រទៅរកជំនួយ ។4នោះគឺជាគំរូនៃអំណាចនៃបំណងប្រាថ្នាដ៏លើសលប់ ! នៅពេលយើងមានការសុបិនមួយ អំពីអ្វីដែលយើងអាចប្រែក្លាយ នោះបំណងប្រាថ្នា និងអំណាចរបស់យើងនៅក្នុងការធ្វើសកម្មភាព គឺមានភាពកើនឡើងយ៉ាងច្រើន ។

យើងភាគច្រើន នឹងមិនជួបប្រទះវិបត្តិដ៏ខ្លាំងដូច្នេះទេ ប៉ុន្តែយើងគ្រប់គ្នា ប្រទះនឹងអន្ទាក់ដ៏ចម្បង ដែលនឹងរារាំងការរីកចម្រើន ទៅរកជោគវាសនាដ៏អស់កល្បជានិច្ចរបស់យើង ។ បើសិនជាបំណងប្រាថ្នាសុចរិតរបស់យើងរឹងមាំគ្រប់គ្រាន់ នោះវានឹងលើកទឹកចិត្តយើងឲ្យដកខ្លួនចេញពីការញៀន និងសម្ពាធ និងអាទិភាពនៃអំពើបាបផ្សេងទៀតដែលរារាំងដល់ការរីកចម្រើនដ៏អស់កល្បរបស់យើង ។

យើងគប្បីចងចាំថា បំណងប្រាថ្នាសុចរិតមិនអាចស្វាក់ស្វើរ ប្រញាប់ប្រញាល់ ឬជារឿងបណ្តោះអាសន្នបានឡើយ ។ វាត្រូវតែចេញពីចិត្តដ៏ស្មោះ មិនងាករេ ហើយមាននិរន្តរភាព ។ វាជាការលើកទឹកចិត្តណាស់ ដែលយើងនឹងរកឃើញស្ថានភាពនោះ ដែលបានពិពណ៌នាដោយ ព្យាការីយ៉ូសែប ស្ម៊ីធ ដែលយើងបាន « យកឈ្នះសេចក្តីអាក្រក់នៃ [ ជីវិតរបស់យើង ] ហើយឈប់ប្រាថ្នាអំពើបាបតទៅទៀត ។ [5] នោះគឺជាការសម្រេចចិត្តផ្ទាល់ខ្លួន ។ ដូចជាអែលឌើរ នែល អេ ម៉ាក់ស្វែល មានប្រសាសន៍ថា ៖

« [ នៅ ] ពេលមនុស្សទូទៅបានពិពណ៌នាថា ‹ ឈប់មានប្រាថ្នាចង់ធ្វើបាប › នោះគឺជាពួកគេតែម្នាក់គត់ដែលបានសម្រេចចិត្តដោយមានបំណងចង់បោះបង់ការប៉ងប្រាថ្នាខុសឆ្គង ដោយមានឆន្ទៈ ‹ លះបង់រាល់អំពើបាប [ របស់ពួកគេ ] ចោល › ដើម្បីមកស្គាល់ព្រះ . . . ។

« ហេតុដូច្នោះហើយ អ្វីដែលយើងប៉ងប្រាថ្នាជាប់ជានិច្ចគឺជា អ្វីដែលយើងនឹងប្រែក្លាយនៅទីបំផុត និងអ្វីដែលយើងនឹងទទួលនៅក្នុងភាពអស់កល្បជានិច្ច » ។ [6]

ជីវិតដ៏នៅអស់កល្បជានិច្ចតម្រូវឲ្យមានកិច្ចការជាច្រើន ដូចគ្នានឹងការបោះបង់គ្រប់បំណងប្រាថ្នាចំពោះអំពើបាបដែរ ។ ដើម្បីសម្រេចជោគវាសនាដ៏អស់កល្បរបស់យើង យើងត្រូវប៉ងប្រាថ្នា ហើយខិតខំស្វែងរកគុណសម្បត្តិដែលធ្វើឲ្យប្រែក្លាយជាមនុស្សដែលមានជីវិតអស់កល្បជានិច្ច ។ ឧទាហរណ៍ មនុស្សដែលមានជីវិតអស់កល្បគឺចេះអភ័យទោសដល់អស់ដែលធ្វើខុសនឹងពួកគេ ។ ពួកគេគិតពីសុខុមាលភាពរបស់អ្នកដទៃមុនខ្លួន ។ ហើយពួកគេស្រឡាញ់

កូនចៅទាំងអស់របស់ព្រះ ។ បើការធ្វើបែបនេះហាក់ដូចជាពិបាកខ្លាំងនោះ — ប្រាកដណាស់ វាមិនងាយស្រួលសម្រាប់យើងណាម្នាក់ទេ — បន្ទាប់មក យើងគួរតែចាប់ផ្ដើម មានបំណងប្រាថ្នាសម្រាប់គុណសម្បត្តិនោះ ហើយទូលទៅព្រះវរបិតាសួគ៌ជាទីស្រឡាញ់របស់យើង ឲ្យជួយដល់អារម្មណ៍របស់យើង ។ ព្រះគម្ពីរមរមនបង្រៀនយើងថា យើងគួរតែ « អធិស្ឋានដល់ព្រះវរបិតាដោយអស់ពីកម្លាំងចិត្ត ដើម្បីឲ្យ[ យើង ]បានពោរពេញ ដោយសេចក្ដីស្រឡាញ់នេះ ដែលទ្រង់បានប្រទានដល់អស់អ្នកណា ដែលជាអ្នកដើរតាមដ៏ពិតនៃព្រះរាជបុត្រារបស់ទ្រង់ គឺព្រះយេស៊ូវគ្រីស្ទ » ( មរ៉ូណៃ 7:48 ) ។

ខ្ញុំសូមបញ្ចប់ជាមួយនឹងឧទាហរណ៍ចុងក្រោយ អំពីបំណងប្រាថ្នាដែលគួរតែសំខាន់បំផុតចំពោះបុរសស្ត្រី —ទាំងអ្នកដែលទើបតែរៀបការ និងអ្នកដែលនៅលីវ ។ ទាំងអស់គ្នាគួរតែមានបំណងប្រាថ្នា និងខិតខំយ៉ាងខ្លាំង ដើម្បីធានាដល់អាពាហ៍ពិពាហ៍សម្រាប់ភាពអស់កល្បជានិច្ច ។ អ្នកទាំងឡាយដែលបានរៀបការក្នុងព្រះវិហារបរិសុទ្ធរួចហើយ គួរតែខំឲ្យអស់ពីលទ្ធភាព ដើម្បីពួកគេអាចរក្សាឲ្យបាន ។ អ្នកទាំងឡាយដែលនៅលីវ គួរតែប៉ងប្រាថ្នាទៅរៀបការនៅក្នុងព្រះវិហារបរិសុទ្ធ ហើយដាក់វាជាអាទិភាព ដើម្បីធ្វើសកម្មភាពទទួលយកវាឲ្យបាន ។ យុវវ័យ និងមជ្ឈិមវ័យវ័យក្មេងគួរតែកុំចុះចូលនឹងភាពត្រឹមត្រូវខាងនយោបាយ ប៉ុន្តែជាគំនិតខុសឆ្គងដ៏អស់កល្បដែលបង្ខូចដល់សារៈសំខាន់នៃការរៀបការ និងការមានកូន ។[7]

បុរសនៅលីវ សូមពិចារណាពីសំណូមពរនៅក្នុងសំបុត្រនេះ ដែលសរសេរដោយបងប្អូនស្រីនៅលីវម្នាក់។ នាងអង្វរថា « បុត្រីសុចរិតរបស់ព្រះ កំពុងតែស្វែងរកដៃគូស័ក្តិសមដោយអស់ពីចិត្ត ប៉ុន្តែបុរស ហាក់ដូចជាមើលមិនឃើញ ហើយបដិសេធ ទោះជាវាជាការទទួលខុសត្រូវរបស់ពួកគេ ឬអត់ ក្នុងការស្វែងរកបុត្រីដ៏ល្អ និងជម្រើសទាំងឡាយរបស់ព្រះវរបិតាសួគ៌យើង ហើយចែចង់ពួកគេ និងព្រមធ្វើ ហើយរក្សាសេចក្តីសញ្ញាដ៏ពិសិដ្ឋនៅក្នុងដំណាក់របស់ព្រះអម្ចាស់ » ។ នាងបានបញ្ចប់ថា ៖ « [ មាន ]បុរស អិល.ឌី.អែស. នៅលីវជាច្រើននៅទីនេះ ដែលរីករាយចូលចិត្តចេញដើរកម្សាន្ត ដើរសប្បាយ ដើរលេងជាគូ ដើរលេងញឹកញាប់ ប៉ុន្តែគ្មានបំណងប្រាថ្នាណាមួយ ធ្វើការតាំងចិត្តទាំងស្រុងចំពោះនារីណាម្នាក់នោះទេ » ។[8]

ខ្ញុំប្រាកដក្នុងចិត្តថា មានយុវជនដែលកំពុងតែរកដៃគូមួយចំនួន អន្ទះសាក្នុងចិត្តចង់ឲ្យខ្ញុំបន្ថែមថា មានយុវនារីមួយចំនួន ដែលដាក់បំណងប្រាថ្នាការរៀបការដោយសក្តិសម និងការមានកូនចៅនៅលំដាប់ទាបជាងបំណងប្រាថ្នាចង់បានអាជីព និងការគោរពរាប់អានក្នុងជីវិតដទៃទៀត ។ ទាំងបុរស និងស្ត្រីត្រូវការបំណងប្រាថ្នាសុចរិត ដែលដឹកនាំពួកគេទៅរកជីវិតដ៏អស់កល្បជានិច្ច ។

សូមឲ្យយើងចាំថា បំណងប្រាថ្នាទាំងឡាយចង្អុលបង្ហាញអំពីអាទិភាពរបស់យើង អាទិភាពទាំងឡាយបង្កើតជាការជ្រើសរើសរបស់យើង ហើយការជ្រើសរើសកំណត់សកម្មភាពរបស់យើង ។បន្ថែមពីលើនោះ គឺជាសកម្មភាព និងបំណងប្រាថ្នារបស់យើង ដែលបណ្ដាលឲ្យយើងប្រែក្លាយ ជាមិត្តស្មោះត្រង់ គ្រូបង្រៀនដែលមានអំណោយទាន ឬ ជាមនុស្សម្នាក់ដែលសមនឹងទទួលជីវិតអស់កល្បជានិច្ច ។
ខ្ញុំថ្លែងទីបន្ទាល់អំពីព្រះយេស៊ូវគ្រីស្ទដែលសេចក្តីស្រឡាញ់ ការបង្រៀន និងដង្វាយធួនបានធ្វើឲ្យអ្វីៗទាំងអស់កើតមានឡើង ។ ខ្ញុំអធិស្ឋានសុំឲ្យយើងមានបំណងប្រាថ្នាចង់ប្រែក្លាយដូចជាទ្រង់លើសអ្វីៗទាំងអស់ ដើម្បីថ្ងៃមួយ យើងអាចត្រឡប់ទៅវត្តមានរបស់ទ្រង់ ដើម្បីទទួលសេចក្ដីអំណរដ៏ពេញលេញរបស់ទ្រង់ ។ នៅក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ អាម៉ែន ។

កំណត់ចំណាំ

1. កំណត់ចំណាំផ្ទាល់ខ្លួនមកពីការសម្ភាសន៍របស់ខ្ញុំជាមួយនឹង រ៉េយ ខក់ Mt. Pleasant, Utah, ថ្ងៃទី 1 ខែ សីហា ឆ្នាំ 1985 បញ្ជាក់អំពីអ្វីដែលគាត់ប្រាប់ខ្ញុំនៅក្នុងទីក្រុងប្រូវ៉ូ រដ្ឋយូថាហ៍ ប្រហែលជាឆ្នាំ 1953 ។

2. សូមមើល Richard C. Roberts, Legacy, The History of the Utah National Guard ទំព័រ 307–14 ( National Guard Association of Utah ឆ្នាំ 2003 ); The National Guardsman ( ទស្សនាវដ្ដី ខែ ឧសភា ឆ្នាំ 1971 ) « Miracle at Kap Yong: The Story of the 213th » ( ខ្សែភាពយន្តផលិតដោយ Southern Utah University ឆ្នាំ 2002 ) ។

3. សូមមើល Aron Ralston, *Between a Rock and a Hard Place* ( រដ្ឋ នូវយោក Atria Books ឆ្នាំ 2004 ) ។

4. Aron Ralston, *Between a Rock and a Hard Place* ទំព័រ 248 ។

5. សូមមើល *Teachings of the Presidents of the Church, Joseph Smith* ( ឆ្នាំ 2007 ) ទំព័រ 51 ។

6. Neal A. Maxwell « According to the Desire of [Our] Hearts » *Ensign* ខែ វិច្ឆិកា ឆ្នាំ 1996 ទំព័រ 21–22 ។

7. សូមមើល Julie B. Beck, « Teaching the Doctrine of the Family » *Liahona* និង *Ensign* ខែ មិនា ឆ្នាំ 2011, 12–17 ។

8. សំបុត្រ ថ្ងៃទី 14 ខែ កញ្ញា ឆ្នាំ 2006 ។